# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
# ព្រៃកប្បាស់ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៩
## ព្រះយេស៊ូបានជ្រើសរើសយើងដើម្បីធ្វើជាសាក្សីនៃដំណឹងល្អ

**អត្ថបទទី១៖ កិច្ចការ ១០,៣៤.៣៧-៤៣**

ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី និងប្រោសប្រទានឲ្យព្រះអង្គបង្ហាញខ្លួន។ កក ១០,៤០

**អត្ថបទទី២៖ កូរិនថូសទី១ ៥,៦-៨**

"មេតែបន្តិចអាចធ្វើឲ្យម្សៅទាំងមូលដោរឡើងបាន!" ១ករ ៥,៦

**ដំណឹងល្អ៖ លូកា ២៤,១-១២**

ទ្រង់មិនគង់នៅទីនេះទេ ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញហើយ។ លក ២៤,៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពព្រះយេស៊ូជាពន្លឺពិសេស ដែលមកបំភ្លឺយើងនៅក្នុងភាពងងឹតនៃជីវិតរបស់យើង។ ពេលស្ត្រីកើតកូន គេថាឆ្លងទន្លេដោយសារកូនក្នុងពោះនៅក្នុងទឹក ពេលចាប់ផ្ដើមធ្លាក់ទឹកមានន័យថាជិតដល់ថ្ងៃឆ្លងទន្លេ។ មានន័យថា កូនចេញពីទឹកនៅក្នុងផ្ទៃពោះដើម្បីមើលឃើញពិភពលោក ហើយនៅពេលនោះកូនយំដោយសារស្ទូតចាប់ផ្ដើមមានសង្ហើមចូល ធ្វើឲ្យស្ទួតហើម។ យើងក៏ដូចគ្នាដែរ បន្តិចទៀតយើងចូលនៅក្នុងទឹក យើងចូលនៅក្នុងទឹកជាមួយព្រះយេស៊ូដើម្បីឆ្លងទន្លេជាមួយព្រះយេស៊ូនិងទទួលជីវិតថ្មី។ ជីវិតដែលយើងបានទទួល ពោរពេញដង្ហើមរបស់យើងគឺព្រះវិញ្ញាណដ៏វិសុទ្ធ ជីវិតរបស់ព្រះយេស៊ូណែនាំឲ្យយើងទៅជាមនុស្សថ្មី។ អត្ថបទទី១ "**ព្រះជាម្ចាស់បានបង្កើតពិភពលោក ព្រះជាម្ចាស់បានបង្កើតទាំងអស់**" មហាកំពូលគឺព្រះជាម្ចាស់បានបង្កើតបុរសនិងស្ត្រី។ បងប្អូនទាំងអស់ដែលអង្គុយនៅទីនេះ ដឹងថាគឺព្រះជាម្ចាស់ដែលបានបង្កើតយើង ឲ្យយើងមានជីវិត ឲ្យយើងមានកម្លាំង ឲ្យយើងបង្កើតកូន ឲ្យថែរក្សាធម្មជាតិទាំងអស់។

យប់នេះ បងប្អូនមួយចំនួនបានទទួលជីវិតពីរ បានទទួលជីវិតពីម្ដាយពេលឆ្លងទន្លេ យប់គឺព្រះជាម្ចាស់ដែលជាព្រះបិតាដែលបង្កើតឲ្យយើងទៅជាមនុស្សថ្មី ឲ្យយើងទទួលជីវិតថ្មី ឲ្យយើងទទួលកម្លាំងថ្មី ឲ្យយើងទទួលសេចក្ដីស្រឡាញ់នៅក្នុងដួងចិត្តរបស់យើង នៅក្នុងខ្លួនរបស់យើងដើម្បីរស់នៅក្នុងសេចក្ដីបច្ចុប្បន្ននេះ។ យប់នេះ យើងសប្បាយចិត្តដោយសារព្រះយេស៊ូប្រទានជីវិតថ្មី ហើយជាអ្វីដែលយើងត្រូវការទទួល។ អត្ថបទគម្ពីរថ្ងៃនេះ "**ព្រះយេស៊ូនៅក្នុងផ្នូរព្រឹកឡើង**

គេមកមើលផ្នូរនេះ ដើម្បីថែរក្សាព្រះយេស៊ូដែលសោយទិវង្គតហើយ គេចង់ដាក់គ្រឿងក្រអូប" អ្នកដែលបានទៅមើលមុនគេបង្អស់ គឺក្រុមស្ត្រី អត់មានគ្រីស្តទូតទេ និងជាស្ត្រីដែលបានទទួលដំណឹងល្អមុនគេបង្អស់។ យើងត្រូវការចាប់អារម្មណ៍ ដោយសារសម័យស្ត្រីអត់មានតម្លៃ ដូច្នេះគេថាស្ត្រីៗទាំងនោះចេះតែនិយាយ គេអត់ទុកចិត្ត ដូច្នេះសក្ខីភាពរបស់ស្ត្រីពីសម័យដើមអត់មានតម្លៃទេ។ ប៉ុន្តែ ព្រះជាម្ចាស់បានជ្រើសរើសស្ត្រីដើម្បីទទួលដំណឹងល្អមុនគេបង្អស់ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ស្ត្រីៗមានកិត្តិយសណាស់ មានមោទនភាពណាស់ ដោយសារព្រះយេស៊ូបានជ្រើសរើសដើម្បីធ្វើជាសាក្សីនៃដំណឹងល្អ។

ស្ត្រីគេមើលផ្នូរទទេ គេស្តាប់ទេវទូតដែលកំពុងនិយាយ នឹងក្រោយមកគេរត់ដើម្បីផ្តល់សក្ខីភាពដល់ក្រុមគ្រីស្តទូត យើងបានឮព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ យើងដឹងថាព្រះយេស៊ូលែងនៅក្នុងផ្នូរ ព្រះយេស៊ូបានឈ្នះភាពងងឹតអស់ហើយ។ ស្ត្រីៗបានឃើញ បានស្តាប់ និងទៅផ្តល់សក្ខីភាព សម្រាប់យើងទាំងអស់គ្នាថ្ងៃនេះ ឲ្យយើងទទួលដំណឹងនេះព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ពេលដែលយើងចេញពីព្រះវិហារនេះ កុំឲ្យយើងភ្លេចបន្តប្រកាសដំណឹងល្អ ព្រះយេស៊ូណែនាំឲ្យខ្ញុំមានជីវិតថ្មី។ ទោះបីយើងទៅណាក៏ដោយ ក៏យើងមានព្រះសហគមន៍ដែលជាមហាគ្រួសាររបស់យើង។ យប់នេះ យើងទទួលជីវិតថ្មី យើងទទួលគ្រួសារថ្មី យើងបានស្តាប់ យើងបានឮ ធ្វើយ៉ាងម៉េចដើម្បីផ្តល់សក្ខីភាព ដើម្បីឲ្យបងប្អូនឯទៀតៗមើលសេចក្តីស្រឡាញ់មេត្តាករុណារបស់ព្រះជាម្ចាស់។ មានតែសេចក្តីស្រឡាញ់និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់សម្រាប់អ្នកជម្ងឺ សម្រាប់អ្នកតូចតាច សម្រាប់មនុស្សដែលគ្មានទីពឹង។ នៅទីនេះ យើងមានប៉ុន្មាននាក់អត់សូវមានទីពឹងនៅក្នុងជីវិត នៅទីនេះយើងមានប៉ុន្មាននាក់ពិបាកណាស់ យើងមានរឿងច្រើនដែលកើតឡើង ប៉ុន្តែយើងមានទីពឹងមួយគឺព្រះសហគមន៍ យើងមានទីពឹងមួយគឺព្រះយេស៊ូ យើងមានទីពឹងមួយគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។

យប់នេះ យើងអរព្រះគុណព្រះជាម្ចាស់ ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា។ អាម៉ែន៕